# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៩៣...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសភាពាណិជ្ជកម្មខេត្តបាត់ដំបង

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦៩៥ / ០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤

## សម្រេច

**មាត្រា ១ .-**

បង្កើតសភាពាណិជ្ជកម្មមួយសំរាប់ខេត្តបាត់ដំបង ហៅថាសភាពាណិជ្ជកម្មខេត្តបាត់ដំបង ព្រំដែនមណ្ឌលសភាពាណិជ្ជកម្មខេត្តបាត់ដំបង គឺកំណត់តាមព្រំដែនខេត្តបាត់ដំបង ។

**មាត្រា ២ .-**

សភាពាណិជ្ជកម្មខេត្តបាត់ដំបង មានសមាជិកជ្រើសតាំងចំនួនដប់ប្រាំរូប (១៥រូប) ដែលជ្រើសរើសតាមការបោះឆ្នោត ។ សភាពាណិជ្ជកម្មខេត្តបាត់ដំបង អាចបង្កើតគណៈកម្មការផ្សេងៗតាមការចាំបាច់ ដើម្បីអភិវឌ្ឍប្រភេទអាជីវកម្មនីមួយៗ ។

**មាត្រា ៣ .-**

តាមសំណើរបស់ប្រធានសភាពាណិជ្ជកម្មខេត្តបាត់ដំបង ក្រសួងពាណិជ្ជកម្មត្រូវកំណត់តាមប្រកាសនូវសមាជិកទីប្រឹក្សាស្របតាមលក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ០៥ នៃច្បាប់ ស្តីពី សភាពាណិជ្ជកម្ម ។

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបាត់ដំបង និងប្រធានសភាពាណិជ្ជកម្មខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០៤

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ដូចមាត្រា ៥
- សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

**ហ៊ុន សែន**